ដំណើរទស្សនៈកិច្ចសិក្សា



# នៅសាលាបឋមសិក្សា ត្រពាំងឪបដើម្បីពង្រឹង សកម្មភាពក្លឹបបរិស្ថាន







Sponsor by

Produce by

Mlup Baitong PO Box 2510. Phnom Penh 3. Cambodia.
Tel/Fax: ++855-23-214-409. Mobile: ++855-12-909-502. e-mail: mlup@online.com.kh



MLUP BAITONG

# បរិស្ថានខ្ញុំ

ព្រឹត្តិបត្រ

ចេញផ្សាយប្រចាំ ត្រីមាស (លេខ១៣) ឆ្នាំទី៤ ខែមេសា_មិថុនា ឆ្នាំ២០០៨

# ភ្លើងឆេះព្រៃ



សិស្សឈ្មោះ ឡេង គន្ធា ថ្នាក់ទី ៦"ក" សាលាព្រៃក្មេង



សិស្សឈ្មោះ ថៃ សារី សាលាសំរោង



សិស្សឈ្មោះ ម៉ម សុខា សាលាពង្រ

ហាមលក់

# អារម្ភកថា

សិស្សឈ្មោះរីម ប៊ុនលីត សាលាទួលសុគី



**សួស្តី!** ប្អូនៗសិស្សានុសិស្សជាទីមេត្រី! ព្រឹត្តិបត្របរិស្ថានខ្ញុំលេខ១៣ នឹងនាំប្អូនៗទៅជួបជាមួយអត្ថបទខ្លីស្តីពី " **ភ្លើងឆេះព្រៃ** " ដែលបានមកពីការចូលរួមក្នុងការសរសេរអត្ថបទស្វែងយល់ សំនួរនិងកំណាព្យ និងគូររូបភាពផ្សេងៗពីសំណាក់លោកគ្រូ អ្នកគ្រូ និងប្អូនៗតាមសាលានានា។ បរិស្ថានខ្ញុំសង្ឃឹមជឿជាក់ថា ប្អូនៗនឹងទទួលបាននូវចំណេះដឹងថ្មីៗ ប្លែកៗទាក់ទងទៅនឹងមូលហេតុនៃគ្រោះមហន្តរាយ និងវិធីការពារភ្លើងឆេះព្រៃដែលមានទៅក្នុងសហគមន៍របស់ប្អូន។



សិស្សឈ្មោះ សយ សេះ

សូមប្អូនៗមានសុខភាពល្អ ប្រាជ្ញាឈ្លាសវៃ ហើយកុំភ្លេចចូលរួមការពារកុំអោយមានភ្លើងឆេះព្រៃទៀត " **ដើមត្នោត** "

## មាតិកា


| | |
|---|---|
| ១- អារម្ភកថា........................២ | ២- អត្ថបទខ្លី...............៣ |
| ៣- អត្ថបទស្វែងយល់.............៤ | ៤- នាទីរឿងខ្លី.............៥ |
| ៥- កំណាព្យ និងចំរៀង............៦ | ៦- ល្បែងសិក្សា............៨ |
| ៧- រឿងខ្លី..............................៨ | ៨- សំនួរត្រិះរិះ.............១០ |
| ៩- សំនួរ ចំលើយ....................១១ | |


អត្ថបទខ្លី

# ភ្លើងឆេះព្រៃ

ព្រៃភ្លើងឆេះ គឺជាបាតុភូតដែលបង្កឡើងដោយមនុស្ស និងធម្មជាតិ ។ ព្រៃឈើមានប្រយោជន៍ច្រើនណាស់ចំពោះ មនុស្ស និងសត្វ ។ ប៉ុន្តែព្រៃឈើត្រូវបានរងនូវការគំរាមកំហែងពីសំណាក់មនុស្សឥតឈប់ឈរ ហើយក្នុងនោះក៏មានបញ្ហាភ្លើងឆេះព្រៃមួយផងដែរ ។ មូលហេតុដែលបណ្តាលអោយមានភ្លើងឆេះព្រៃមានកត្តាពីរសំខាន់គឺ

☝ កត្តាធម្មជាតិ : ដូចជាផ្លូវផ្លាក់ទង្គិចគ្នា រន្ទះបាញ់....។ បាតុភូតនេះពុំសូវមានញឹកញាប់ទេ វីក៏កំរនឹងមានណាស់នៅក្នុងប្រទេសយើង ។

✌ កត្តាមនុស្ស : ដូចជា ដុតព្រៃចាប់សត្វ ចោលកន្ទុយបារី ចំអិនអាហារក្នុងព្រៃមិនបានពន្លត់ភ្លើង ដុតរានដីព្រៃដើម្បីដាំដំណាំ ដុតព្រៃលេង... ។ល។ ភ្លើងឆេះព្រៃបណ្តាលអោយបាត់បង់ព្រៃឈើ សត្វព្រៃ និងអនុផលព្រៃឈើជាច្រើនទៀត ហើយវាក៏អាចបណ្តាលអោយមានគ្រោះថ្នាក់ដល់មនុស្សផងដែរ ។

ដូចនេះដើម្បីការពារភ្លើងឆេះព្រៃ យើងទាំងអស់គ្នាគួរតែរួមចំណែកផ្សព្វផ្សាយពីមូលហេតុហេតុបណ្តាលអោយមានភ្លើងឆេះព្រៃ និងវិធីការពារកុំអោយមានភ្លើងឆេះព្រៃក្នុងសហគមន៍របស់យើងដូចជា: ពេលចំអិនអាហាររួចត្រូវពន្លត់ភ្លើង កុំដុតព្រៃចាប់សត្វ កុំចោលភ្លើងក្នុងព្រៃ ចូលរួមពន្លត់ភ្លើងព្រៃ ។ល។

# អត្ថបទស្ដីពីផលប៉ះពាល់ ភ្លើងឆេះព្រៃ


សិស្សឈ្មោះ ស៊ុន មករា

ព្រៃឈើ គឺជាប្រភពធនធានធម្មជាតិមិនអាចខ្វះបាន សំរាប់មនុស្ស និងសត្វ ។ ព្រៃឈើបានផ្ដល់ផលប្រយោជន៍ច្រើនយ៉ាងដូចជា សំណង់ អាហារ ថ្នាំ .... ។ ប៉ុន្តែព្រៃឈើនេះក៏ត្រូវបានទទួលការបំផ្លាញពីសំណាក់មនុស្ស និងធម្មជាតិផងដែរ ។ រដូវប្រាំងស្លឹករុក្ខជាតិគ្រប់ប្រភេទតែងតែទំជ្រុះឬក្រៀមស្វិតដោយសារខ្វះជាតិទឹក ។ គេប្រទះឃើញមានភ្លើងឆេះព្រៃជាញឹកញាប់នៅរដូវប្រាំង ។ ផលវិបាកដែលបណ្ដាលមកពីភ្លើងឆេះព្រៃមានដូចជា:

-បំផ្លាញដល់ជំរកសត្វព្រៃ និងប្រភេទឈើប្រណិតដែលមានតំលៃ

-សំលាប់សត្វព្រៃ


សិស្សឈ្មោះ សឿន ដាវ៉ុណា

-បង្កើនការហូរច្រោះដី

-បន្ថយការដុះលូតលាស់របស់កូនរុក្ខជាតិតូចៗ នឹងដើមឈើធំៗត្រូវថយការលូតលាស់ផងដែរ ។

-បន្ថយសារធាតុខនិជ និងជីជាតិដី( ឧទាហរណ៍: ស្លឹកឈើដែលងាប់នឹងរលួយក្លាយជាជីត្រូវភ្លើងឆេះកំទេចទៅជាផេះ) ។

-បន្ថយសំណើមក្នុងដី និងធ្វើអោយជង្រៅមទឹកក្រោមដីកាន់តែជ្រៅ ។ល ។



# រឿងខ្លី ការភ្ញាក់រលឹកទាន់ពេល

នៅព្រឹកថ្ងៃអាទិត្យមួយ**សំ**បានដើរកំសាន្តនៅឯព្រៃ ក៏ប្រទះឃើញ**ឃ្លុញ**បំរុងដុតព្រៃ **សំ**សួរថា :

**សំ:** **ឃ្លុញ** តើឯងកំពុងធ្វើអ្វីហ្នឹង?

**ឃ្លុញ:** ខ្ញុំកំពុងរៀបចំដុតព្រៃ រកសត្វណា៎ មកជួយគ្នាអោយលឿនបានសត្វធ្វើម្ហូប ។ តូចៗ

**សំ:** ទេ! ឯងធ្វើនេះខុសហើយសំលាញ់ ព្រោះការដុតព្រៃវាបណ្ដាលអោយងាប់ដល់រុក្ខជាតិ និងសត្វគ្រប់ប្រភេទ ហើយមិនតែប៉ុណ្ណោះវាបណ្ដាលអោយសត្វវិនាសព្រាត់ប្រាស់គ្នាទៀតផង ។

**ឃ្លុញ:** នែ៎ **សំ**!ឯងគិតតែពីខ្លាចនេះខ្លាចនោះវាគ្មានស្អីទេ! ហើយព្រៃនេះមិនមែនជារបស់យើងឯណា!កុំគិតច្រើនពេក( ប្រញាប់និយាយបណ្ដើរ ដុតព្រៃបណ្ដើរ) ។ ភ្លើងក៏ចាប់ផ្ដើមឆាបឆេះសន្ធោរសន្ធៅ **ឃ្លុញ**ភ័យណាស់ក៏ស្រែកហៅ**សំ**អោយជួយពន្លត់ ។

**ឃ្លុញ:** **សំ**ជួយផង! ជួយផង!ភ្លើងឆេះព្រៃខ្លាំងណាស់ ( អ្នកទាំងពីរក៏ជួយពន្លត់គ្នា រហូតដល់ភ្លើងរលត់)

**សំ:** នេះហើយ គឺលទ្ធផលដែល**ឃ្លុញ**ឯងបានប្រព្រឹត្ត ។ តើឯងឃើញទេវាមានអ្វីកើតឡើងដូចដែលខ្ញុំបានប្រាប់ឯងពីមុននោះដែររឺទេ?

**ឃ្លុញ:** ហ៊ឺ! ខ្ញុំសោកស្ដាយណាស់ ដែលមិនស្ដាប់ការណែនាំរបស់សំលាញ់ឯង ។ ខ្ញុំសន្យាថាលែងប្រព្រឹត្តដូចពេលនេះទៀតហើយ និងជួយអប់រំដល់មិត្តភក្តិក្នុងសហគមន៍យើង ។

**សំ:** ល្អហើយសំលាញ់!យើងត្រូវជួយការពារសម្បត្តិធម្មជាតិអោយគង់វង្ស ដើម្បីអោយកូនចៅយើងស្គាល់ និងរស់នៅប្រកបដោយសេចក្ដីសុខតរៀងទៅ ។


សិស្សឈ្មោះ ឃឿន ភន ថ្នាក់ទី ៥ សាលាត្រពាំងឪម

# កំណាព្យ

## ផលវិបាកនៃភ្លើងឆេះព្រៃ

ព្រៃឈើស្រុកខ្មែរ    មានច្រើនហូរហែរ    សំបូរមិនខ្វះ
ដើមតូចដើមធំ    ដុះច្រើនស្អេកស្កះ    ផ្តល់ផលច្រើនណាស់
មរតកដូនតា ។

ព្រៃឈើបានផ្តល់    ជារុក្ខផល    ច្រើនគ្រប់ប្រការ
មានដើមមានវល្លិ៍    មើមស្លឹកផ្លែផ្កា    ជីវផ្សិតផងណា
សំបូរអនេក ។

ពេលភ្លើងឆេះព្រៃ    ងាប់សព្វអ្វីៗ    សត្វរត់យំស្រែក
ព្រាត់មេព្រាត់បា    ទុក្ខសោកសង្វេក    ឃើញស្រក់ទឹកភ្នែក
សែនអនិច្ចា ។

យើងជាកូនខ្មែរ    រួមគ្នាខំថែ    សម្បត្តិអស្ចារ្យ
ការពារភ្លើងឆេះ    កុំធ្វេសឡើងណា    បន្ថយដុតផ្កា
បរិស្ថានល្អ ។



សិស្សឈ្មោះ វ៉ាន់ ចូ ថ្នាក់ទី ៥



សិស្សឈ្មោះ ជុន មេត្តា សាលាពង្រ



# ចំរៀងបទ

## ភ្លើងឆេះព្រៃ

និពន្ធដោយលោកគ្រូ សុខ សាន សាលាបឋមសិក្សាបន្ទាប់(ឈើនាំមកបុណ្យនៃចេក្រ)

១- ដើរកាត់ព្រឹក្សព្រៃវែច្រៀងបំពេ    សូរិយាយាងរើពិសបូព៌ា
បក្សាបក្សីក្នុងព្រៃព្រឹក្សា    ចរចេញយាត្រាលោចាកទ្រង់ ។

២- ហើរហោះបោះពួយព្រួយក្នុងឱរ៉ា    កាត់ព្រៃព្រឹក្សាតាមចង្កេះភ្នំ
ចិត្តសែនខ្សឹកខ្សួលឆេះឆួលក្តៅងំ    ព្រោះឃើញព្រៃភ្នំត្រូវបានវិនាស ។

៣- ភ្លើងព្រៃឆាបឆេះផេះភ្លួលមីដាស់    ផ្សែងឆួលជ្រួលទៅនៅលើអាកាស
បក្សីបក្សាឱរ៉ាផ្សាប្រេះ    ខំហើរគេចវេះពីភ្លើងកំណាច ។

៤- ឱ! កូនខ្មែរអើយត្រូវជួយការពារ    ព្រៃឈើកម្ពុជាធនធានធម្មជាតិ
ព្រៃព្រឹក្សម្រឹគសល់ឈើដុះព្រោងព្រាត    នេះជាធម្មជាតិកេរ្តិ៍ពីដូនតា ។



សិស្សឈ្មោះ ញ៉ឹប សំអុល ថ្នាក់ទី៥ សាលាត្រពាំងឪឫប



# ល្បែងសិក្សា

សូមជួយរកផ្លូវទៅផ្ទះខ្ញុំផង ដោយឆ្លងកាត់រង្វង់ចេកចំនួន៩ផ្លែ

និងទៅដល់ផ្ទះរបស់ខ្ញុំ។




" ឈើមួយដើមអាចផលិតឈើគូសបាន១០០០០០

ហើយឈើគូស១ក៏អាចបំផ្លាញឈើបាន១០០០០០ដើមដែរ "



# រឿងខ្លី ចាបស្រុក និង ចាបព្រៃ

នៅលើដើមឈើក្បែរភូមិមួយចំងាយប្រហែលជា២គីឡូម៉ែត្រ ពីព្រៃមានចាបស្រុកមួយហ្វូងកំពុងពិភាក្សាគ្នាពីការរកចំណី ។ នៅខណៈពេលដែលគេកំពុងចរចារគ្នា ស្រាប់តែមានចាបព្រៃមួយហ្វូងហោះចេញពីព្រៃដោយភាពភ័យខ្លាច ។

**ចាបស្រុក:** អេ បង តើបងមានការអ្វី អីក៏ភ័យខ្លាចម្លេះ?

**ចាបព្រៃ:** បងអើយ ខ្ញុំហើរចេញពីព្រៃ បងដឹងទេ ព្រៃជាជំរកដែលយើងធ្លាប់រស់នៅតាំងពីយូរមកហើយនោះ ឥឡូវវាកំពុងតែឆេះភ្លើងវាក្តៅណាស់ ខ្ញុំមិនអាចទ្រាំបានទេ ។

**ចាបស្រុក:** អើបង ចុះសំបុកដែលបងរស់នៅយូរមកហើយនោះ ហេតុអីបានជាវាឆេះអញ្ចឹង?

**ចាបព្រៃ:** បងអើយ ពេលដែលខ្ញុំកំពុងតែបញ្ចុកចំណីកូនរបស់ខ្ញុំក្នុងសំបុក ខ្ញុំឃើញមានមនុស្សមួយក្រុមគេបំពក់ភ្លើងដាំបាយ ហើយនិយាយថា គេដុតព្រៃចាប់សត្វ ។ ( ចាបព្រៃផ្សេងទៀតនិយាយ ) ចំណែកសំបុកខ្ញុំវិញដែលស្ថិតនៅជាប់និងមាត់ផ្លូវនោះ ខ្ញុំឃើញមានអ្នកដំណើរខ្លះទៀតបានចោលកន្ទុយបារី ហើយមួយសន្ទុះក្រោយមកក៏មានអណ្តាតភ្លើងឆាបឆេះឡើងតែម្តង ។

**ចាបស្រុក:** ហើយចុះបងឯងបំរុងនឹងហើរទៅណាហ្នឹង?

**ចាបព្រៃ:** បាទបង ខ្ញុំគ្មានជំរកទៀតទេ បងដឹងទេ ខ្ញុំព្រាត់កូនរបស់ខ្ញុំមិនដឹងជានៅទីណាទេ ។ បងប្អូនដែលរស់នៅជំគ្នាឥឡូវបែកគ្នាអស់ហើយ ។ ពេលនេះខ្ញុំគ្មានអ្វីទៀតទេ គ្រាន់តែសំអោយមនុស្សទាំងឡាយ កុំដុតបំផ្លាញធម្មជាតិ ដុតព្រៃចាប់សត្វ បំផ្លាញជំរកយើងទៀត ។

# សំនួរ ត្រិះរិះ



១- តើព្រៃឈើវិនាសហិនហោចដោយសារអ្វីខ្លះ?

.....................................................................................................

.....................................................................................................

២- តើភ្លើងឆេះព្រៃបណ្តាលមកពីកត្តាអ្វីខ្លះ? ចូររៀបរាប់?

.........................................................................................

.........................................................................................



សិស្សឈ្មោះ ហួត គីមលាង សាលាត្រពាំងឪប

៣- នៅប្រទេសកម្ពុជាតើពីខែណា ដល់ខែណាដែលភ្លើងងាយឆេះព្រៃជាងគេ?

.........................................................................................

.........................................................................................



# សំនួរ ? ចំលើយ

១- តើភ្លើងឆេះព្រៃបណ្តាលអោយមានគ្រោះថ្នាក់អ្វីខ្លះដល់រុក្ខជាតិ និងសត្វ?

(ឈ្មោះ ថេង ប៊ុនថុង សាលាបឋមសិក្សាបន្ទាប់)

ចំលើយ: ភ្លើងឆេះព្រៃបណ្តាលអោយងាប់ដើមឈើ កូនឈើទើបនឹងដុះ និងបាត់បង់ អនុផលព្រៃឈើ ចំនែកសត្វព្រៃត្រូវងាប់ឬរត់ទៅកន្លែងផ្សេង។

២- តើយើងត្រូវធ្វើដូចម្តេចដើម្បីកុំអោយមានភ្លើងឆេះព្រៃ?

(ឈ្មោះ ឈិវ ឧសភា សាលាបឋមសិក្សាបន្ទាប់)

ចំលើយ: (សូមប្អូនមើលនៅក្នុងទំព័រអត្ថបទស្វែងយល់)

៣- តើភ្លើងឆេះព្រៃបណ្តាលមកពីអ្វី?

(ឈ្មោះ សាត សុផាត សាលាបឋមសិក្សាបន្ទាប់)

ចំលើយ: (សូមប្អូនមើលនៅក្នុងទំព័រអត្ថបទខ្ទី) ។



សិស្សឈ្មោះ ឃួច សារ៉ុម ថ្នាក់ទី

៤- ពេលដែលអ្នកដំណើរទៅព្រៃ ហេតុអ្វីបានជាធ្វើអោយមានឆេះព្រៃ (ឈ្មោះ ឃឿន ភន សាលាបឋមសិក្សាត្រពាំងឪប)

ចំលើយ: ពីព្រោះអ្នកដំណើរទាំងនោះប្រើប្រាស់ភ្លើងមិនបានប្រុងប្រយ័ត្នដូចជាការ បោះគូទបារីចោល ដាំបាយមិនបានពន្លត់ ដុតព្រៃចាប់សត្វជាដើម ។



សិស្សឈ្មោះ ឃឿន ភុន សាលាព្រៃក្មេង